**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របៀបប្រើប្រាស់

# ប្រព័ន្ធអនឡាញចុះបញ្ជីកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំង

User Manual

Tour Package Registration System

## សម្រាប់ការីទេសចរណ៍

For Tour Operator

www.tpr.visitcambodia.travel

ឆ្នាំ២០២១

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. គោលបំណង ........ 1

៣. ដំណើរការរបស់ប្រព័ន្ធ ........ 2

៤. ការចុះឈ្មោះក្នុងប្រព័ន្ធ ........ 2

៥. ផ្ទាំង Dashboard ........ 3

៦. មុខងារ Tour Package ........ 4

៧. មុខងារ Tourists ........ 7

៨. មុខងារ Tour Guide - មគ្គុទ្ទេសក៍ទេសចរណ៍ ........ 9

៩. មុខងារ Notification - រាយការណ៍ ........ 10

១០. មុខងារ Survey - ស្ទង់មតិយោបល់ ........ 11

# ១. សេចក្តីផ្តើម

ប្រព័ន្ធអនឡាញចុះបញ្ជីកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំង គឺជាប្រព័ន្ធសម្រាប់សហការីទេសចរណ៍ស្នើសុំការចុះបញ្ជីកញ្ចប់ទស្សនកិច្ចនៅក្នុងបរិបទនៃជំងឺកូវីត-១៩ និងជំរុញការគ្រប់គ្រងច្បាស់លាស់លើកញ្ចប់ទស្សនកិច្ចនាំទេសចរ ចូលមកទស្សនាកម្ពុជា តាំងពីការរៀបចំកញ្ចប់ រហូតដល់ការដាក់ឱ្យដំណើរការ និងការបញ្ចប់ទៅវិញនៃកញ្ចប់ទស្សនកិច្ចនីមួយៗ កាត់បន្ថយហានិភ័យដែលអាចប៉ះពាល់ដល់ភ្ញៀវទេសចរ ប្រជាជនមូលដ្ឋាន និងសុខភាពសាធារណៈដែលបណ្តាលមកពីការរីករាលដាល់នៃជំងឺកូវីត-១៩។ ប្រព័ន្ធនេះ ក៏បានភ្ជាប់ទៅប្រព័ន្ធវិធានសុវត្ថិភាពទេសចរណ៍តាមគោលដៅនឹងសម្បទានទេសចរណ៍ដែលរៀបចំឡើងដោយក្រសួងទេសចរណ៍ និងមានប្រព័ន្ធរាយការណ៍ពីព្រឹត្តិការណ៍នានាដែលអាចកើតមានឡើងក្នុងដំណាក់កាលដំណើរកម្សាន្តរបស់ភ្ញៀវទេសចរនៃកញ្ចប់ទស្សនកិច្ច។ ក្រៅពីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រងកញ្ចប់ទស្សនកិច្ចសុវត្ថិភាព ក៏ត្រូវមានការចូលរួមពីការីទេសចរណ៍ ភ្នាក់ងារទេសចរណ៍ មគ្គុទ្ទេសក៏ទេសចរណ៍ និងភ្ញៀវផងដែរ ទៅលើការអនុវត្តវិធាន៣កុំ ៣ការពារ និងវិធានផ្សេងទៀតរបស់រដ្ឋាភិបាល ដើម្បី ធានាថាដំណើរកម្សាន្តរបស់ភ្ញៀវនៃកញ្ចប់ទស្សនកៈកិច្ចគឺមានសុវត្ថិភាពពីជំងឺឆ្លង Covid-19 និងផ្តល់ទំនុកចិត្តដល់ភ្ញៀវអន្តជាតិដល់គោលដៅទេសចរណ៍កម្ពុជា។ ប្រព្វន័អនឡាញនេះក៏បានចូលរួមគាំទ្រដល់ការបើកទេសចរណ៍កម្ពុជាឡើងវិញ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងក៏អាចផ្តល់ទន្និន័យនឹងការវិភាគ ឬក៏របាយការណ៍ដែលពាក់ព័ន្ធនឹងកញ្ចប់ទស្សនកិច្ចនវានុវត្តថ្មីៗ ដែលបានគិតគូរក្នុងគ្រប់ខណ្ឌនៃសភាពការណ៍តាមបរិបទនៃគន្លងទម្លាប់ថ្មី ស្របតាមផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិ Covid-19។

# ២. គោលបំណង

ប្រព័ន្ធកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំង ត្រូវបានបង្កើតឡើងក្នុងគោលបំណង៖

- ផ្តល់នូវប្រព័ន្ធអនឡាញដល់ការីទេសចរណ៍សម្រាប់រៀបចំកញ្ចប់ទស្សៈកិច្ចទេសចរណ៍មានសុវត្ថិភាព និងមានការគ្រប់គ្រងច្បាស់លាស់ មានប្រព័ន្ធរាយការណ៍ និងភ្ជាប់ទៅប្រព័ន្ធវិធានសុវត្ថិភាពទេសចរណ៍តាមគោលដៅ និងសម្បទាទេសចរណ៍ដែលរៀបចំឡើងដោយក្រសួងទេសចរណ៍
- កសាងទំនុកចិត្តសម្រាប់ទេសចរអន្តរជាតិមកលើគោលដៅទេសចរណ៍កម្ពុជាឡើងវិញ និងបង្ហាញថាជាគោលដៅមានសុវត្ថិភាពជាទីទុកចិត្ត និងកក់ក្តៅ
- គាំទ្រ និងចូលរួមការបើកទេសចរណ៍កម្ពុជាឡើងវិញរបស់រាជរដ្ឋាភិបាលជាមួយវិធានការ ដែលមានជាធរមាន
- ផ្តល់ការវិភាគ និងរបាយការណ៍ពាក់ព័ន្ធកញ្ចប់ទស្សនកិច្ចថ្មីសម្រាប់ការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រគ្រប់គ្រងកាន់តែប្រសើរ
- គាំទ្រផ្នែកឯកជនក្នុងវិស័យទេសចរណ៍តាមទីផ្សារនីមួយៗ និងតាមគោលដៅទេសចរណ៍ក្នុងការរៀបចំការធ្វើដំណើរតាមបែបគន្លងនៃទម្លាប់ថ្មី ( New Normalization ) ។
- ស្តារវិស័យទេសចរណ៍ និងសេដ្ឋកិច្ចនៅតាមគោលដៅទេសចរណ៍អាទិភាពដែលមានសុវត្ថិភាព និងមានហានិភ័យទាប

# ៣. ដំណើរការរបស់ប្រព័ន្ធ

ខាងក្រោមនេះជាដំណើររួមនៃប្រព័ន្ធចុះបញ្ជីកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំង៖




រូបភាពទី១

# ៤. ការចុះឈ្មោះក្នុងប្រព័ន្ធ

- ការីទេសចរណ៍ដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួងទេសចរណ៍អាចចុះឈ្មោះក្នុង ប្រព័ន្ធកញ្ចប់ទស្សនកិច្ចទេសចរណ៍សុវត្ថិភាព ដោយចូលទៅកាន់គេហទំព័រ **www.tpr.visitcambodia.travel** រួចចូលទៅកាន់ ប៊ូតុង Register a new membership និងបំពេញព័ត៌មានមូលដ្ឋានក្នុងទម្រង់ដូចរូបភាពទី២។
- ក្រោយបំពេញព័ត៌មានលម្អិតរបស់ខ្លួនរួច លោកអ្នកចុចលើប៊ូតុង Register ដើម្បីបញ្ជូន ទិន្នន័យនេះមកកាន់ក្រុមការងារបច្ចេកទេសក្រសួងទេសចរណ៍ដើម្បីពិនិត្យ និងសម្រេចក្នុងការដាក់ដំណើរការគណនីរបស់អ្នក។ ប៉ុន្តែរាល់ការបង្កើតគណនីទាំងអស់ លោកអ្នកត្រូវតែប្រើប្រាស់ address E-mail ពិតប្រាកដ ដើម្បីធ្វើការបញ្ជាក់ពីប្រព័ន្ធ។ សារបញ្ជាក់ "Message" នោះ, អ្នកនឹងទទួលបានភ្លាមៗក្រោយពេលចុះឈ្មោះ រួចនៅក្នុងប្រអប់សារ "Inbox" របស់អ្នក ឬ Spam mail។

- ករណីលោកអ្នកមិនបានទទួលបានសារសូមទំនាក់ទំនងមកកាន់ក្រុមការងារជំនាញបន្ថែម។ This User is not active or approved ដូច (រូបភាពទី៣) បញ្ជាក់ថាគណនីរបស់លោកអ្នកមិនទាន់បាន បញ្ជាក់នៅក្នុងប្រអប់សារ "Inbox" ដែលប្រព័ន្ធបានផ្ញើទៅទេ។

- ករណីលោកអ្នកទទួលបានជោគជ័យលើការបញ្ជាក់ ប្រព័ន្ធនឹងបង្ហាញសារដូច (រូបភាពទី៤)។ សារត្រូវបញ្ជូនទៅក្នុង E-mail របស់អ្នកបន្ថែមទៀត ដែលបញ្ជាក់ពីការយល់ព្រម និងសម្រេចដាក់ឱ្យដំណើរការគណនីរបស់លោកអ្នក។




រូបភាពទី២




រូបភាពទី៣




រូបភាពទី៤

## ៥. ផ្ទាំង Dashboard

ផ្ទាំង Dashboard ឬគេហទំព័រដើម របស់គណនីអ្នក នឹងបានបង្ហាញរាល់កញ្ចប់ទស្សនកិច្ចដែលកំពុង ឬបានចុះបញ្ជី និងសកម្មភាពផ្សេងកំឡុងដំណើរកម្សាន្ត (Tracking Activity)។ លោកអ្នកនឹងឃើញ ផ្ទាំង Dashboard ដូច(រូបភាពទី៥) និងមុខងារសំខាន់ៗ៖




រូបភាពទី៥

- Home សម្រាប់ត្រលប់មកផ្ទាំង Dashboard ឬទំព័រដើមវិញ
- Tour Package សម្រាប់បង្កើត ឬពិនិត្យមើលកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំង
- Tour Guide សម្រាប់ពិនិត្យមើលទិន្នន័យមគ្គុទ្ទេសក៍ទេសចរណ៍ ឬបង្កើតថ្មី
- Tourists សម្រាប់បញ្ចូលព័ត៌មានភ្ញៀវទេសចរក្នុងកញ្ចប់ទស្សនកិច្ច ឬពិនិត្យព័ត៌មានរបស់ភ្ញៀវក្នុងកញ្ចប់ទស្សនកិច្ចណាមួយ
- Notification សម្រាប់ផ្តល់ព័ត៌មានឬជូនដំណឹងដល់ក្រសួងទេសចរណ៍
- Account Setting សម្រាប់ការកំណត់ផ្សេងៗក្នុងគណនីអ្នក
- Logout ចាក់ចេញពីប្រព័ន្ធកញ្ចប់ទស្សនកិច្ចទេសចរណ៍សុវត្ថិភាព

នៅពេលលោកអ្នកចុចលើកញ្ចប់ទស្សនកិច្ចនីមួយៗ នឹងចេញព័ត៌មានលម្អិត ដូច(រូបភាពទី១០) ដែលលោកអ្នកអាច view, edit, add tourists, register ។ល។ ប៉ុន្តែមិនអាច Delete បានទេ បើកញ្ចប់នោះត្រូវបានយល់ព្រមដោយក្រសួងទេសចរណ៍ និងមិនទាន់ហួសសុពលភាព។

ចំណាំ៖ រាល់កញ្ចប់ទស្សនកិច្ចដែលបានបង្កើត និងបញ្ចប់ជោគជ័យ យើងអាចយកមកបង្កើត និងប្រើប្រាស់ម្តងទៀតបានដោយចុចលើប៊ូតុង  ដែលមាននៅលើផ្ទាំង Dashboard ក្នុង Action។

## ៦. មុខងារ Tour Package

Menu កញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំង (Tour Package), អាចឱ្យលោកអ្នកបង្កើតកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងថ្មីដែលក្នុងនោះមានភ្ជាប់ទៅនឹងប្រព័ន្ធវិធានសុវត្ថិភាពទេសចរណ៍ របស់ក្រសួងទេសចរណ៍ដែលផ្តល់ឱ្យលោកអ្នកនូវជម្រើសទីតាំង ឬសម្បទាទេសចរណ៍ដែលទទួលបានការបញ្ជាក់វិធានសុវត្ថិភាពទេសចរណ៍ពីក្រសួងទេសចរណ៍។ មុននឹងបង្កើតកញ្ចប់ ទស្សនៈកិច្ចថ្មីលោកអ្នកត្រូវត្រៀមនូវព័ត៌មាននិងឯកសារ Scan ចាំបាច់ដូចជារូបភាពកន្លែងកម្សាន្ត, សកម្មភាព ឬទីតាំងផ្សេងៗដែលមានក្នុងកញ្ចប់ទស្សនកិច្ច។ សូមបញ្ចូលកញ្ចប់ និងស្នើសុំចុះបញ្ជីយ៉ាងហោចណាស់ឱ្យបាន ១៥ថ្ងៃ មុនថ្ងៃកំណត់នៃដំណើរកម្សាន្តចាប់ផ្តើមដើម្បីឱ្យក្រសួងទេសចរណ៍បញ្ជូនទៅភាគីពាក់ព័ន្ធ។

ខាងក្រោមនេះជាទម្រង់ដែលត្រូវបំពេញព័ត៌មានកញ្ចប់ទស្សនកិច្ច៖

*ចំណាំ៖ សម្រាប់ចំណុច ( * ) ពណ៌ក្រហម មិនអាចទទេរបានទេ។*

**កញ្ចប់ទស្សនកិច្ចមួយមានព័ត៌មានសំខាន់ ០២ផ្នែក គឺ ព័ត៌មានទូទៅ និងព័ត៌មានពីខ្សែទស្សនកិច្ច** (Itinerary) **ដូចជា៖**

១. General Information (រូបភាពទី៦) ព័ត៌មានទូទៅដែលត្រូវបំពេញ

- Package Name: ឈ្មោះកញ្ចប់ទេស្សនៈកិច្ច
- Arrival date: ថ្ងៃខែឆ្នាំមកដល់កម្ពុជា
- Departure: ថ្ងៃខែឆ្នាំបញ្ចប់ដំណើរកម្សាន្ត និងចេញពីកម្ពុជា

- Market: ជ្រើសរើសប្រទេសរបស់ភ្ញៀវទេសចរដែលទិញកញ្ចប់ទស្សនកិច្ច។ ករណីភ្ញៀវទេសចរចំរុះជាតិសាស្ត្រ ត្រូវជ្រើសរើស (mixed market)
- Number of Days: ចំនួនថ្ងៃនៃកញ្ចប់ទស្សនកិច្ច
- Hotel Quarantine: ជ្រើសរើសសណ្ឋាគារចត្តាឡីស័ក
- Insurance Company & Policy Number: បំពេញឈ្មោះក្រុមហ៊ុនធានារ៉ាប់រង និងលេខទំនាក់ទំនង
- Tour Guide: ជ្រើសរើសមគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់កញ្ចប់ទស្សនកិច្ច
- Description: ព័ត៌មានលម្អិតបន្ថែមពីកញ្ចប់ទស្សនកិច្ច
- Price of Package: តម្លៃនៃកញ្ចប់ទស្សនកិច្ច




រូបភាពទី៦

២. Itinerary (Day) ព័ត៌មានពីខ្សែទស្សនកិច្ច (រូបភាពទី៧) ដែលក្នុងនោះបែងចែកទៅតាមថ្ងៃ ពេលវេលា និងសកម្មភាពសំខាន់ៗ ដូចជាការទស្សនា, ការស្នាក់នៅ, ភោជនីយដ្ឋាន ។ល។

- Program Name: ឈ្មោះកម្មវិធីនៅក្នុងថ្ងៃដំណើរកម្សាន្តមួយ
- Date: ថ្ងៃខែឆ្នាំកញ្ចប់ទស្សនកិច្ច
- Description: ព័ត៌មានលម្អិតបន្ថែម

បញ្ជាក់៖ យើងអាចបន្ថែម ថ្ងៃ ដោយចុចលើប៊ូតុង 




រូបភាពទី៧

៣. Itinerary (Activity) ព័ត៌មានពីខ្សែទស្សនកិច្ចលម្អិត (រូបភាពទី៨) ដែលក្នុងនោះសម្រាប់បំពេញព័ត៌មានលម្អិតដូចខាងក្រោម៖

- Time: ពេលវេលាដែលដល់ទីតាំងនីមួយៗ
- Location: រាជធានីខេត្តទាំង ២៥
- Type: ប្រភេទអាជីវកម្មដែលបានកំណត់ដោយក្រសួងទេសចរណ៍
- Place: ឈ្មោះទីតាំង ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍
- Activity: សកម្មភាពដែលត្រូវធ្វើពេលទៅដល់ទីតាំង
- Detail: បំពេញបទ័មានលម្អិតបន្ថែម




រូបភាពទី៨

ចំពោះ Itinerary (Day) លោកអ្នកអាចបញ្ចូលថ្ងៃបន្ថែមដោយចុចលើប៊ូតុង + Add Day + Add Day ។ រីឯសកម្មភាព Itinerary (Activity) យើងចុចប៊ូតុងសញ្ញា បូក នេះសម្រាប់ ថែមម៉ោងនៃសកម្មភាព និងសម្រាប់ការបន្ថែមលើថ្ងៃ។

ក្រោយបញ្ចូលទិន្នន័យតាមទម្រង់របស់កញ្ចប់ទស្សនកិច្ចសុវត្ថិភាព រួចសូមចុចប៊ូតុង Save ករណីចង់រក្សាទិន្នន័យទុកសិន, Register ករណីស្នើសុំចុះបញ្ជីកញ្ចប់ទស្សនកិច្ចនេះ ឬ View ករណីចង់មើលទម្រង់បោះពុម្ព នៃកញ្ចប់ទស្សនកិច្ចផ្សេងៗ។ សូមចូលទៅមើលផ្ទាំង Dashboard ផ្នែក Tour Package Not Registered បង្ហាញពីឈ្មោះ ចំនួនថ្ងៃ និងទម្រង់ផ្សេងៗដូច(រូបភាពទី៩)៖






រូបភាពទី៩

- **ការពិនិត្យមើលកញ្ចប់ទស្សនកិច្ចដែលបានបញ្ចូលហើយ៖** នៅលើ Dashboard សូមចុចលើឈ្មោះកញ្ចប់ទស្សនកិច្ចដែលលោកអ្នកចង់ពិនិត្យមើល។ លោកអ្នកនឹងឃើញសន្លឹក ឬទំព័រកញ្ចប់ទស្សនកិច្ចដូច(រូបភាពទី១០)។




## ៧. មុខងារ Tourists

រូបភាពទី១០

ការីទេសចរណ៍អាចបញ្ចូលបញ្ជីភ្ញៀវទេសចរដែលបានទិញកញ្ចប់ទស្សនកិច្ចដែលបានចុះបញ្ជីហើយ។ ការបញ្ចូលទិន្នន័យភ្ញៀវទេសចរជាកាតព្វកិច្ចចាំបាច់របស់ការីទេសចរណ៍នៅពេលលក់កញ្ចប់ទស្សនកិច្ចណាមួយ។ ក្រសួងទេសចរណ៍រក្សាព័ត៌មានទាំងនេះមិនឱ្យមានការប្រើប្រាស់ណាក្រៅពីគោលបំណងធានាសុវត្ថិភាពទាំងភ្ញៀវទេសចរ និងប្រជាជនក្នុងសហគមន៍ពីជំងឺឆ្លងកូវីដ-១៩។ សូមចុចលើ Menu Tourist បញ្ចូលទិន្នន័យរបស់ភ្ញៀវទេសចរដូច (រូបភាពទី១១) នៃកញ្ចប់ទស្សនកិច្ចណាមួយដែលក្នុងនោះមានដូចជាព័ត៌មានទូទៅ៖ ឈ្មោះ, ភេទ, ថ្ងៃខែឆ្នាំកំណើត, លិខិតឆ្លងដែន និង ព័ត៌មានពីសុខភាព ដូចជា វិញ្ញាបនបត្រចាក់វ៉ាក់សាំង ឬលិខិតបញ្ជាក់ពីការព្យាបាលសះស្បើយពីកូវីដ-១៩ ផ្សេងៗ (រូបភាពទី១២)៖

*សម្រាប់ * រាល់ព័ត៌មានទាំងអស់ត្រូវបញ្ចូលក្នុងប្រព័ន្ធ ជាចាំបាច់។*




រូបភាពទី១១




រូបភាពទី១២

ផ្ទាំងបញ្ចូលព័ត៌មានវ៉ាក់សាំង៖ សម្រាប់បញ្ចូលលេខកាតចាក់វ៉ាក់សាំង, ប្រភេទឈ្មោះវ៉ាក់សាំង, បានចាក់រួចប៉ុន្មានដូស និងកាលបរិច្ឆេតដែលបានចាក់ចុងក្រោយគេបង្អស់ និងការផ្តល់នូវឯកសារផ្សេងៗមកកាន់ប្រព័ន្ធ។




រូបភាពទី១៣

ផ្ទាំងព័ត៌មានពីការជាសះស្បើយ៖ សម្រាប់បញ្ចូលនូវព័ត៌មានរបស់ភ្ញៀវដែលធ្លាប់ជាសះស្បើយពីជំងឺកូវីដ-១៩ , ថ្ងៃខែឆ្នាំ នៃការជាសះស្បើយ និងឯកសារបញ្ជាក់ផ្សេងៗ។




រូបភាពទី១៤

ផ្ទាំងព័ត៌មានពីការតេស្តនូវជំងឺកូវីដ-១៩៖ សម្រាប់បញ្ចូលព័ត៌មាន ប្រភេទនៃការតេស្តស្វែងរកជំងឺ, ការបរិច្ឆេតតេស្តចុងក្រោយ និងភ្ជាប់នូវឯកសារពាក់ព័ន្ធ។

សម្រាប់ទិន្នន័យភ្ញៀវទេសចរបានបញ្ចូលរួចយើងអាចកែសម្រួល ឬលុបចេញពីប្រព័ន្ធបានដោយប្រើប្រាស់ប៊ូតុង Delete និង Edit។ ប៉ុន្តែករណីកញ្ចប់ទស្សនកិច្ចនោះ Active (កំពុងដំណើរការ) លោកអ្នកមិនអាចលុបព័ត៌មានភ្ញៀវទេសចរបានទេ។ លោកអ្នកបញ្ចូលបន្ថែមព័ត៌មានមានភ្ញៀវទេសចរផ្សេងៗទៀតទៅក្នុងកញ្ចប់ទស្សនកិច្ចលើប៊ូតុង + ដូច (រូបភាពទី១៤)។




រូបភាពទី១៤

## ៨. មុខងារ Tour Guide - មគ្គុទ្ទេសក៍ទេសចរណ៍

មគ្គុទ្ទេសក៍ទេសចរណ៍គឺជា អ្នកដឹកនាំភ្ញៀវពន្យល់ណែនាំភ្ញៀវក្នុងដំណើរកញ្ចប់ទស្សនកិច្ចក្នុង និងអាចរាយការណ៍ពីដំណើរការកម្សាន្តរបស់ភ្ញៀវមកកាន់ការីទេសចរណ៍ ដែលរៀបចំកញ្ចប់ទស្សនកិច្ចនេះ។ ការី ឬទីភ្នាក់ងារទេសចរណ៍អាចបញ្ចូលព័ត៌មានរបស់មគ្គុទ្ទេសក៍ទេសចរណ៍ដែលបានជួលដឹកនាំដំណើរកម្សាន្តកញ្ចប់ទស្សនកិច្ចដោយចុចុលើប៊ូតុង Tour Guide។ ដើម្បីបញ្ចូនទិន្នន័យមគ្គុទ្ទេសក៍ទេសចរណ៍ចុចលើប៊ូតុង +Add ដូចរូបខាងក្រោម៖




រូបភាពទី១៥

សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ លោកអ្នកនឹងត្រូវបំពេញព័ត៌មានដូចខាងក្រោម (រូបភាពទី ១៦) រាល់ព័ត៌មានទាំងអស់គឺត្រូវតែបំពេញ៖

*បញ្ជាក់៖ សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍មានការបែងចែកតាមប្រភេទដូចជា៖ថ្នាក់ក្រោមជាតិ, ថ្នាក់តំបន់, ថ្នាក់ទំនាក់ទំនង និងថ្នាក់ពិសេស។




រូបភាពទី១៦

## ៩. មុខងារ Notification - រាយការណ៍

ការីទេសចរណ៍ត្រូវរាយការណ៍ជូនក្រសួងទេសចរណ៍ ករណីមានសកម្មភាព ឬព្រឹត្តិការណ៍មិនប្រក្រតីកើតឡើងលើភ្ញៀវទេសចរ។ សូមចុចលើ Menu Notification ដើម្បីរាយការណ៍ដូច (រូបភាពទី១៧)៖

ដំណើរការនៃការរាយការណ៍ យើងត្រូវជ្រើសរាល់កញ្ចប់ទស្សនកិច្ច រួចជ្រើសរើសភ្ញៀវដែលមានបញ្ហាក្នុងករណីចាំបាច់ (បើករណីជាហេតុការណ៍ជារួម) មិនបាច់បំពេញទេ។ Message សម្រាប់បំពេញព័ត៌មានលម្អិតនៃហេតុការណ៍នោះ។ បន្ថែមរូបភាពជាចាំបាច់នៅខាងក្រោម រួចចុចបញ្ជូន។




រូបភាពទី១៧

## ១០. មុខងារ Survey - ស្ទង់មតិយោបល់

ការីទេសចរណ៍នឹងទទួលបានការស្ទង់មតិយោបល់ពាក់ព័ន្ធនឹងកញ្ចប់ទស្សនកិច្ចតាមកម្រងសំណួរដូច (រូបទី១៨) ខាងក្រោម៖




រូបភាពទី១៨




ក្រោយបញ្ចូល Survey ខ្លីរួច លោកអ្នកនឹងទទួលបានសារ ដូចរូបខាងឆ្វេង។ រាល់ទិន្នន័យទាំងអស់នឹងរក្សាទុកក្នុងប្រព័ន្ធ។